រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

031KH01A-01

ច្រៀងចំរៀងថ្វាយព្រះអម្ចាស់



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៣១

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



អាន និង រិះគិតពិចារណាអំពីទំនុកតម្កើង ១៥០ ។

សូមគូសសញ្ញានេះ «✓» ក្នុងប្រអប់ «□» នេះ ពេលដែលអ្នក
បានរិះគិតពិចារណាអំពីទំនុកតម្កើង ១៥០រួចហើយ ។

ការច្រៀងសរសើរជាផ្នែកសំខាន់ណាស់របស់ការប្រជុំថ្វាយបង្គំ ។
យើងសំដែងសេចក្តីស្រឡាញ់ និង អំណររបស់យើងចំពោះ
ព្រះជាម្ចាស់ជាព្រះអាទិករ និងព្រះសង្គ្រោះរបស់យើង ហើយ
លើកតម្កើងព្រះអង្គជាព្រះដ៏ធំខ្ពស់បំផុត និងមានព្រះហឫទ័យ
មេត្តាករុណា តាមរយៈបទចំរៀង និងទំនុកតម្កើង ។ មួយវិញ
ទៀត យើងក៏លើកទឹកចិត្តគ្នាទៅវិញទៅមក អោយជឿរកឡើងក្នុង
ជំនឿលើព្រះគ្រីស្ត តាមរយៈការច្រៀងសរសើរដែរ ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

២ របាក្សត្រ ៥:១២-១៤ ពន្យល់អំពីរបៀបសរសើរតម្កើង ដែលគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ សូមអានវគ្គព្រះគម្ពីរនេះពេលនេះ ។

យើងច្រៀងសរសើរ ដើម្បី :

☐ ធ្វើអោយយើងសប្បាយចិត្ត ។

☐ អោយគាប់ព្រះហឫទ័យព្រះជាម្ចាស់ ។

ស្តេចសាឡូម៉ូននាំយកហិបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ ទៅដាក់ក្នុងព្រះវិហារថ្មី ។ មនុស្សរាប់រយនាក់ដើរតាមគាត់ ហើយច្រៀង និងលេងភ្លេងដើម្បីសរសើរតម្កើងព្រះជាម្ចាស់ ។ ពេលយើងដឹកនាំក្រុមជំនុំអោយច្រៀង គោលបំណងរបស់យើង គឺដឹកនាំក្រុមជំនុំទាំងមូលអោយថ្វាយបង្គំព្រះជាម្ចាស់ ។

នៅក្នុង ២ របាក្សត្រ ៥ ព្រះជាម្ចាស់បានបង្ហាញថាព្រះអង្គពេញព្រះហឫទ័យណាស់ចំពោះការសរសើរតម្កើងរបស់គេ ។

ព្រះអង្គក៏បង្ហាញសិរីល្អ និងវត្តមានរបស់ព្រះអង្គដល់គេ តាមរយៈ :

☐ ពពក ។

☐ ព្រះសូរសៀង ។

© Project WorldReach © SEAN

ប្រភេទផ្សេងៗនៃបទចំរៀង

ដើម្បីសាងសង់ផ្ទះមួយ គេត្រូវដឹងអំពីប្រភេទផ្សេងៗនៃសម្ភារៈសំណង់ ។ ដូចគ្នានេះដែរ ដើម្បីដឹកនាំការថ្វាយបង្គំក្នុងក្រុមជំនុំ យើងក៏ចាំបាច់ត្រូវដឹងអំពីប្រភេទផ្សេងៗនៃចំរៀងដែរ ដើម្បីអោយយើងអាចប្រើបទចំរៀងអោយសមទៅតាមកាលៈទេសៈ នៅក្នុងការថ្វាយបង្គំ ។

នៅក្នុងព្រះគម្ពីរទំនុកតម្កើង មានប្រធានបទផ្សេងៗគ្នា គឺមានទំនុកតម្កើងថ្វាយបង្គំ ទំនុកតម្កើងសរសើរតម្កើង ទំនុកតម្កើងទួលសួម ទំនុកតម្កើងសារភាពអំពើបាប ទំនុកតម្កើងទីបន្ទាល់ ទំនុកតម្កើងដាស់តឿន ឬ ទំនុកតម្កើងបង្រៀន ។ គេច្រើនតែឃើញថា នៅក្នុងទំនុកតម្កើងមួយ មានប្រធានបទច្រើនរួមជាមួយគ្នា ។

សៀវភៅចំរៀងខ្លះ មានតារាងប្រធានបទនៅដើមសៀវភៅ ។ តារាងនេះបង្ហាញបទចំរៀងតាមប្រធានបទ ដូចជា បទចំរៀងថ្វាយបង្គំ បទចំរៀងទីបន្ទាល់ បទចំរៀងសួមអញ្ជើញ បទចំរៀងថ្វាយខ្លួន ។ល។ ។ យើងអាចដឹងពីប្រភេទរបស់ទំនុកតម្កើង និងបទចំរៀង ដោយមើលពាក្យពេចន៍របស់ចំរៀងបានដែរ ។

កំណត់ចំណាំ

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនពួកតន្ត្រីកររបស់ក្រុមជំនុំ និងពួកអ្នកដឹកនាំថ្វាយបង្គំ អំពីតួនាទីតន្ត្រី និងការច្រៀង ក្នុងការថ្វាយបង្គំ ។ អ្នកអាចប្រើទំនុកតម្កើង ១00 ឬ វគ្គព្រះគម្ពីរផ្សេងទៀត ដែលមានដាក់ជូនក្នុងការសិក្សានេះ ។

- រៀបចំពួកតន្ត្រីករទៅតាមតួនាទីសំរាប់កម្មវិធីថ្វាយបង្គំ ។

- ណែនាំពួកអ្នកដឹកនាំកម្មវិធីថ្វាយបង្គំ ពីរបៀបជ្រើសរើស និងដឹកនាំបទចំរៀង ។

- បង្រៀនក្រុមជំនុំពីរបៀបច្រៀងអោយកាន់តែល្អ ។

- ទន្ទេញអេភេសូ ៥:១៩ អោយចាំ ។

- តែងចំរៀងថ្វាយបង្គំមួយដោយប្រើពាក្យពេចន៍អ្នកផ្ទាល់ ។

បទចំរៀង**ថ្វាយបង្គំ**រៀបរាប់អំពីសិរីរុងរឿង ភាពខ្ពស់ឧត្តម និងភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ ។ នៅពេលថ្វាយបង្គំ យើងតម្រង់ចិត្តទៅរកព្រះជាម្ចាស់ ហើយឈប់គិតពីខ្លួនឯង ។ ការថ្វាយបង្គំធ្វើអោយចិត្តយើងរំភើបឡើង ។ ពេលយើងច្រៀងចំរៀងថ្វាយបង្គំ យើងនិយាយទៅកាន់ព្រះជាម្ចាស់ មិនមែននិយាយទៅកាន់គ្រីស្ត-ជនឯទៀតទេ ។

តាមរយៈបទចំរៀងថ្វាយបង្គំ យើងនិយាយទៅកាន់ :

☐ ព្រះជាម្ចាស់ ។

☐ គ្រីស្តជនឯទៀត ។

ទំនុកតម្កើង**សរសើរតម្កើង**និយាយអំពីកិច្ចការធំៗរបស់ព្រះ-ជាម្ចាស់ ។ ឧទាហរណ៍ :

«ឱព្រះអម្ចាស់អើយ សត្វលោកដែលព្រះអង្គបានបង្កើតមក នឹងនាំគ្នាលើកតម្កើងព្រះអង្គ ហើយប្រជាជនរបស់ព្រះអង្គ ក៏នឹងនាំគ្នាសរសើរតម្កើងព្រះអង្គដែរ ។ គេនឹងរៀបរាប់អំពីព្រះរាជ្យដ៏រុងរឿងរបស់ព្រះអង្គ គេនឹងថ្លែងអំពីឫទ្ធានុភាពរបស់ព្រះអង្គ ដើម្បីអោយមនុស្សទាំងអស់បានដឹងពីការអស្ចារ្យរបស់ព្រះអង្គ និងសិរីរុងរឿងដ៏ភ្លឺចិញ្ចែងចិញ្ចាចនៃព្រះរាជ្យរបស់ព្រះអង្គ » ។

(ទំនុកតម្កើង ១៤៥:១0-១២)

ការថ្វាយបង្គំ គឺការជាផ្ចង់ចិត្តគំនិតទៅរកព្រះជាម្ចាស់ផ្ទាល់ និងគិតអំពីចរិតលក្ខណៈរបស់ព្រះអង្គ ឯការសរសើរតម្កើង គឺជាការផ្ចង់ចិត្តគំនិត គិតអំពីកិច្ចការដ៏ធំឧត្តមរបស់ព្រះអង្គ ។ ទោះជាដូច្នេះក៏ដោយ ក៏ការសរសើរតម្កើង និងការថ្វាយបង្គំស្រដៀងគ្នាណាស់ ។ ដូច្នេះពេលខ្លះ ពិបាកនឹងបែងចែកការសរសើរតម្កើងពីការថ្វាយបង្គំណាស់ដែរ ។

តើទំនុកតម្កើងប្រភេទណា ដែលនិយាយអំពីកិច្ចការដ៏ធំឧត្តមរបស់ព្រះជាម្ចាស់ ? ការសរ _____

បទចំរៀង**ទីបន្ទាល់** និយាយអំពីខ្លួនយើងផ្ទាល់ (ជំនឿរបស់យើង បំណងប្រាថ្នារបស់យើងចង់ដើរតាមព្រះយេស៊ូគ្រីស្ត និងកិច្ចការដែលព្រះអង្គបានធ្វើសំរាប់យើង) ។

តើបទចំរៀងប្រភេទណា ដែលរៀបរាប់ពីខ្លួនយើង និងរៀបរាប់អំពីអ្វីៗដែលព្រះជាម្ចាស់បានធ្វើចំពោះយើង ? គឺបទចំរៀង :

☐ ទីបន្ទាល់ ។

☐ ថ្វាយបង្គំ ។

៥- តើអ្នកត្រូវរកអោយឃើញក្លូនសោភ្លេងរបស់ចំរៀង នៅពេលណា ?

_____

៦- សូមសរសេរឧទាហរណ៍ចំរៀង ឬ ខព្រះគម្ពីរដកស្រង់ពីទំនុកតម្កើងទាំងបួនប្រភេទខាងក្រោម សំរាប់ដឹកនាំពួកអ្នកជឿអោយថ្វាយបង្គំ :

ទីបន្ទាល់ :

_____

អរព្រះគុណ :

_____

សរសើរតម្កើង :

_____

ថ្វាយបង្គំ :

_____

© Project WorldReach © SEAN

៣- ពួកអ្នកដឹកនាំចំរៀង ប្រើរបៀបផ្សេងៗ ដើម្បីដឹកនាំប្រជា-រាស្ត្ររបស់ព្រះជាម្ចាស់ អោយថ្វាយបង្គំព្រះជាម្ចាស់ដោយវិញ្ញាណ ប្រកបដោយប្រសិទ្ធិភាព ។ អ្នកប្រហែលជាអនុវត្តរបៀបដឹកនាំផ្សេងគ្នាពីអ្នកដឹកនាំឯទៀត ។ ការសំខាន់ គឺអ្នកត្រូវផ្លាស់ប្តូររបៀបដឹកនាំ ស្របទៅតាមកាលៈទេសៈ និង ប្រភេទមនុស្សដែលអ្នកដឹកនាំ ។ សូមសរសេរឧទាហរណ៍ខាងក្រោមនេះ អំពីរបៀបដែលអ្នកនឹងរៀបចំគំរោងសំរាប់ដឹកនាំសមាជិករបស់អ្នក ក្នុងកម្មវិធីថ្វាយបង្គំ ដែលនាំអោយសមាជិករួមចិត្តយ៉ាងជិតសិទ្ធជាមួយព្រះជាម្ចាស់ដ៏មានអំណាចខ្ពស់បំផុត ។

_____

_____

_____

_____

៤- តើចំរៀងមួយណា ដែលសមរម្យជាងសំរាប់សេចក្តីអធិប្បាយអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូ ?

☐ « យប់ដ៏សុខសាន្ត យប់បរិសុទ្ធ » ។

☐ « ខ្ញុំរង់ចាំទ្រង់ » ។

ចំរៀងទីបន្ទាល់ ដូចជា « ឥឡូវនេះ ខ្ញុំបានដឹងជាក់ហើយ » បង្ហាញអំពីបទពិសោធន៍ និងសេចក្តីសង្ឃឹមរបស់យើង ។ ចំរៀងទីបន្ទាល់រៀបរាប់ពីខ្លួនយើង ។

« ត្បូងទ្រង់រើស » ជាបទចំរៀង :

☐ ទីបន្ទាល់ ។

☐ ថ្វាយបង្គំ ។

ទំនុកតម្កើង**ទូលសូម** រៀបរាប់អំពីការដែលយើងត្រូវទូលសុំអ្វីមួយពីព្រះជាម្ចាស់ ។

ទំនុកតម្កើង ១៤0:២ ចែងថា÷ *« ឱ ព្រះអម្ចាស់ សូមរំដោះទូលបង្គំអោយរួចពីមនុស្សអាក្រក់ សូមការពារទូលបង្គំអោយផុតពីមនុស្សយោរយៅ »* ។

តើទំនុកតម្កើងនេះទូលសុំអ្វី ? _____

ទំនុកតម្កើង ៥៧:២ ចែងថា÷ *« សូមអាណិតមេត្តាទូលបង្គំ ឱ ព្រះជាម្ចាស់អើយ សូមអាណិតមេត្តាទូលបង្គំផង »* ។

ខ គម្ពីរនេះជា :

☐ ការទូលសូម ។

☐ ការថ្វាយបង្គំ ។

ទំនុកតម្កើងខ្លះទៀត បានរៀបរាប់ពីសេចក្តីដែលមនុស្សបានទូលសូមអោយព្រះជាម្ចាស់កំទេចខ្មាំងសត្រូវ ។ ទំនុកតម្កើងដូចនេះមានតែនៅក្នុងសម្ពន្ធមេត្រីចាស់ទេ ។ នៅក្នុងសម្ពន្ធមេត្រីថ្មី ព្រះអម្ចាស់បង្គាប់អោយយើងប្រទានពរដល់សត្រូវរបស់យើង ព្រមទាំងអធិស្ឋានសំរាប់ពួកគេផងដែរ (ម៉ាថាយ ៥:៤៣-៤៤)។

ទំនុកតម្កើង ៦៨:២ ចែងថា÷ *«ពេលព្រះជាម្ចាស់ក្រោកឡើង ខ្មាំងសត្រូវរបស់ព្រះអង្គបាក់ទ័ព »* ។

ខ គម្ពីរនេះជា :

☐ ការអធិស្ឋានប្រឆាំងនឹងខ្មាំងសត្រូវ ។

☐ ទំនុកតម្កើងថ្វាយបង្គំ ។

បទចំរៀង**ដាស់តឿន** លើកទឹកចិត្តយើងអោយប្រតិបត្តិតាមព្រះជាម្ចាស់ ។

«ទ្រង់ប្រុងចាំជួយ »

☐ ថ្វាយបង្គំ ។

☐ ទីបន្ទាល់ ។

«ឱ ! ព្រះយេស៊ូអើយ ទូលបង្គំសន្យាថា នឹងបំរើព្រះអង្គរហូតដល់ទីបញ្ចប់ »

☐ ទូលសូម ។

☐ ថ្វាយខ្លួនទាំងស្រុង ។

«សូមបើកភ្នែកទូលបង្គំ »

☐ ទូលសូម ។

☐ ស្វាគមន៍ ។

«មកតម្កើងព្រះអង្គ ! »

☐ ទីបន្ទាល់ ។

☐ ដាស់តឿន ។

© Project WorldReach © SEAN

ទំនុកតម្កើង ៣៤:៥ : « *ខ្ញុំបានអង្វរព្រះអម្ចាស់ ព្រះអង្គក៏ឆ្លើយតបមកខ្ញុំវិញ ព្រះអង្គបានរំដោះខ្ញុំអោយរួចពីការភ័យខ្លាច ទាំងអម្បាលម៉ាន* » ។

ទំនុកតម្កើង ១៩:១ : « *ផ្ទៃមេឃថ្លែងអំពីសិរីរុងរឿងរបស់ព្រះជាម្ចាស់ អាកាសវេហាស៍ប្រកាសអំពីស្នាព្រះហស្តរបស់ព្រះអង្គ* » ។

ទំនុកតម្កើង ៦៣:១ : «*ឱព្រះជាម្ចាស់អើយ ! ព្រះអង្គពិតជាព្រះនៃទូលបង្គំមែន ទូលបង្គំស្វែងរកព្រះអង្គ* » ។

២- សូមគូសសញ្ញានេះ «✓» ក្បែរប្រភេទត្រឹមត្រូវរបស់ចំរៀងនិមួយៗខាងក្រោមនេះ :

«ព្រះបិតា ខ្ញុំជំពឹងទ្រង់ »

☐ ថ្វាយបង្គំ ។

☐ ទូលសូម ។

ចំរៀង «ទៅមុខគ្រីស្តជនអើយ » ។ បង្ហាញពី :

☐ ការថ្វាយបង្គំ ។

☐ ការដាស់តឿន ។

បទចំរៀងនេះ ជាការដាស់តឿន ព្រោះឃ្លានេះលើកទឹកចិត្តយើងអោយបំរើព្រះអម្ចាស់ ដោយចិត្តក្លាហាន ទៅមុខកុំរាថយ ។

នៅក្នុងបទចំរៀង**អរព្រះគុណ** យើងអរព្រះគុណព្រះជាម្ចាស់ចំពោះផលប្រយោជន៍គ្រប់យ៉ាង ដែលយើងបានទទួល ។

នៅក្នុងបទចំរៀង**ថ្វាយខ្លួន** យើងថ្វាយជីវិតយើងទាំងស្រុង ទៅព្រះអម្ចាស់ ដើម្បីបំរើព្រះអង្គ ។

«សូមព្រះអង្គទទួលយកជីវិត... ពេលវេលា... ដៃ... ជើង... តង្វាយ... តម្រិះ ...» បង្ហាញពី :

☐ ការលន់តួសារភាពអំពើបាប ។

☐ ការថ្វាយខ្លួន ។

នៅក្បែរចំណងជើងចំរៀងខាងក្រោមនេះ សូមសរសេរប្រភេទចំរៀងទាំងនោះ ដែលមាន «ថ្វាយបង្គំ» «ទីបន្ទាល់» «អរព្រះគុណ» ឬ «សរសើរតម្កើង» :

ក) «ខ្ញុំសូមតាំងទ្រង់ឡើង» _____

ខ) «ខ្ញុំបានរស់ហើយ» _____

គ) «អរព្រះគុណព្រះសង្គ្រោះ» _____

ឃ) «ពេលទឹកជន់ ទ្រង់បានសំដែងបារមី» _____

ង) «ព្រះវរបិតា យើងលើកតម្កើងទ្រង់» _____

ចំលើយ :

ក) ថ្វាយបង្គំ (ចំរៀងនេះ យើងប្តេជ្ញាចិត្តតាំងទ្រង់ឡើង) ។

ខ) ទីបន្ទាល់ (ចំរៀងនេះនិយាយពីបទពិសោធន៍របស់មនុស្សម្នាក់) ។

គ) អរព្រះគុណ ។

ឃ) សរសើរតម្កើងអំពីកិច្ចការដ៏ធំឧត្តមរបស់ព្រះជាម្ចាស់ ។

ង) ថ្វាយបង្គំ (ផ្ចង់ចិត្តគំនិតទៅរកព្រះអម្ចាស់) ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- ខព្រះគម្ពីរទាំងឡាយខាងក្រោមនេះ ដែលដកស្រង់ពីទំនុកតម្កើង និយាយអំពីទីបន្ទាល់ ការលន់តួសារភាពអំពើបាប ការសរសើរតម្កើង ការថ្វាយខ្លួនទាំងស្រុងទៅព្រះអម្ចាស់ ឬការថ្វាយបង្គំ ។ នៅក្បែរខនិមួយៗ សូមសរសេរប្រភេទរបស់ខព្រះគម្ពីរនោះ :

ទំនុកតម្កើង ៤៨:១ : *«ព្រះអម្ចាស់ជាព្រះដ៏ប្រសើរឧត្តមដែលត្រូវតែលើកតម្កើងអោយខ្ពង់ខ្ពស់បំផុត»* ។

_____

ទំនុកតម្កើង ៥១:២ : *«សូមលុបលាងកំហុសទូលបង្គំអោយបានស្អាតទាំងស្រុង សូមជំរះទូលបង្គំអោយបានបរិសុទ្ធរួចពីបាប !»* ។

_____

ទំនុកតម្កើង ១៨:១ : *«ឱព្រះអម្ចាស់អើយ ទូលបង្គំស្រឡាញ់ព្រះអង្គ ព្រោះព្រះអង្គជាកម្លាំងរបស់ទូលបង្គំ !»*

_____

© Project WorldReach © SEAN

ជួយសមាជិកគ្រប់គ្នាឱ្យអាចច្រៀងស៊ីសង្វាក់គ្នា ។ ដើម្បីអាចធ្វើដូចនេះបាន គ្រប់គ្នាត្រូវ :

- សំឡឹងមើលអ្នកដឹកនាំ ដើម្បីច្រៀងអោយត្រូវសង្វាក់គ្នា ។
- ច្រៀងពាក្យចំរៀងអោយច្បាស់លាស់ ។
- ច្រៀងសទ្ទសញ្ញា(លេខភ្លេង)ខ្ពស់ដោយសម្លេងច្រៀងគឺមិនមែនស្រែក ឬបន្តឹងសម្លេងទេ ។

- ច្រៀងដោយល្បឿនសមរម្យ សំរាប់ប្រភេទចំរៀងនិមួយៗ ។ ចំរៀងនិយាយពីអំណរ និងការលើកទឹកចិត្ត ត្រូវច្រៀងលឿនជាងចំរៀងផ្សេងៗទៀត ។ ចំរៀងសំរាប់ជំរុញឱ្យរិះគិតពិចារណា ត្រូវច្រៀងយឺតជាង ស្របទៅតាមបទភ្លេង ។

- ណែនាំមនុស្សអោយគិតអំពីពាក្យចំរៀង ដែលពួកគេកំពុងច្រៀង ដើម្បីឱ្យពួកគេអាចថ្វាយបង្គំព្រះជាម្ចាស់ ដោយស្មោះស្ម័គ្របាន ។

- ក្នុងកម្មវិធីថ្វាយបង្គំ ត្រូវចេះចុះចូលចំពោះការណែនាំ និងការបំភ្លឺរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ ព្រះអង្គអាចមានព្រះហឫទ័យចង់បន្ថែម ឬ ផ្លាស់ប្តូរអ្វីមួយ ។

របៀបដែលចំរៀងនាំក្រុមជំនុំអោយថ្វាយបង្គំ

នៅក្នុងសម្ពន្ធមេត្រីចាស់ ពួកយូដានាំគ្នាឡើងទៅទីក្រុងយេរូសាឡឹម ដើម្បីប្រារព្ធធ្វើពិធីបុណ្យ ។ ពេលដើរទៅជិតដល់ទីក្រុងយេរូសាឡឹម ពួកយូដានាំគ្នាច្រៀងចំរៀង « បទចំរៀងសំរាប់ឡើងទៅព្រះវិហារ » (ទំនុកតម្កើង ១២០-១៣៤) ។

នៅពេលដែលគេច្រៀងបទចម្រៀងសំរាប់ឡើងទៅព្រះវិហារទាំងនេះ ដំបូង គេច្រៀងរៀបរាប់ពីសេចក្តីត្រូវការរបស់មនុស្ស ដូចជា « នៅពេលមានអាសន្ន ខ្ញុំស្រែកអង្វរព្រះអម្ចាស់ » (ទំនុកតម្កើង ១២០:១) ហើយពេលដែលគេចូលទៅក្នុងព្រះវិហាររបស់ព្រះជាម្ចាស់ គេច្រៀងសរសើរតម្កើងព្រះអង្គ ដើម្បីបញ្ចប់ (ទំនុកតម្កើង ១៣៤:១-៣) ។ ចាប់ពីសេចក្តីត្រូវការរបស់មនុស្ស ទៅដល់វត្តមានរបស់ព្រះជាម្ចាស់ មានចមាយវែងណាស់ ប្រហែលជាដូចនេះហើយ បានជាពួកគេច្រៀងទំនុកតម្កើងចំនួនដល់ទៅដប់ប្រាំបទ ។

ចំរៀងអាចនាំអោយយើង ងើបឡើងពីបន្ទុកប្រចាំថ្ងៃនៃជីវិតរបស់យើង ទៅដល់វត្តមានរបស់ព្រះជាម្ចាស់ ។ ប៉ុន្តែ ដើម្បីឱ្យអាចសរសើរតម្កើងព្រះជាម្ចាស់ឱ្យអស់ពីចិត្ត និងដោយស្ម័គ្រស្មោះបាន

យើងត្រូវដឹកនាំចំរៀង ដោយនឹកចាំពីគោលដៅនេះជានិច្ច ។
បើមិនដូច្នេះទេ ចំរៀងគ្រាន់តែធ្វើអោយធ្លុះស្រាលក្នុងអារម្មណ៍ប៉ុណ្ណោះ ហើយការធ្លុះស្រាលក្នុងអារម្មណ៍ មិនមែនជាការថ្វាយ-បង្គំព្រះជាម្ចាស់ ដោយវិញ្ញាណ និងដោយសេចក្តីពិតនោះទេ ។

មនុស្សភាគច្រើនអាចដឹកនាំចំរៀងបាន ប៉ុន្តែ ដើម្បីដឹកនាំមនុស្សអោយថ្វាយបង្គំ យើងត្រូវការមនុស្សពិសេសម្នាក់ ដែលមានអំណោយទានខាងការដឹកនាំការថ្វាយបង្គំ ។ បើសិនជាអ្នកដឹកនាំការថ្វាយបង្គំចង់ដឹកនាំអ្នកដទៃឱ្យចេះថ្វាយបង្គំ ដោយសេចក្តីពិតនោះគាត់ផ្ទាល់ត្រូវចេះថ្វាយបង្គំ ដោយសេចក្តីពិតសិន ។
អ្នកដឹកនាំការថ្វាយបង្គំ ត្រូវដឹង :

- អំពីគោលដៅនៃកម្មវិធីថ្វាយបង្គំ ។
- អំពីរបៀបចាប់ផ្តើមការថ្វាយបង្គំ ដែលស្របនឹងគោលដៅនេះ ។
- អំពីជំហានទៅរកគោលដៅនេះ ។
- អំពីពេលដែលក្រុមជំនុំបានឈានដល់ការថ្វាយបង្គំ ដោយវិញ្ញាណ និង ដោយសេចក្តីពិតហើយ ។

ចំលើយ : អ្នកដឹកនាំចំរៀងខាងស្តាំត្រូវ សិតសក់ មានទឹកមុខញញឹម ស្លៀកពាក់អោយបានសមរម្យ បោកសំអាត និង ប៉ះខោរបស់គាត់ ឈរអោយត្រង់ខ្លួន កោរពុកមាត់ ។ល។...។

ក្នុងកម្មវិធីថ្វាយបង្គំ

- មកដល់មុនពេលចាប់ផ្តើមកម្មវិធី ។
- ធ្វើយ៉ាងណាឱ្យអ្វីៗគ្រប់យ៉ាង បានរៀបរយជាស្រេចដូចជា :
  - រឹតឧបករណ៍ភ្លេងអោយមានសម្លេងត្រឹមត្រូវ ។
  - លំដាប់លំដោយនៃបទចំរៀង ។
  - ជួយក្រុមជំនុំអោយចេះពាក្យចំរៀងទាំងអស់ ឬ ចែកក្រដាសចំរៀងសំរាប់អោយក្រុមជំនុំអាន ឬ បញ្ចាំងក្រដាសឬស្ទីកបទចំរៀងទៅលើជញ្ជាំង ។
- អធិស្ឋាន និងរៀបចំចិត្តគំនិតជាមួយក្រុមដឹកនាំការថ្វាយ-បង្គំ ។
- អ្នកលេងភ្លេងត្រូវចាប់ផ្តើមលេងបទដែលត្រូវច្រៀង ហើយ

- ប្រាប់ឱ្យដឹងមុន ដល់អ្នកដែលត្រូវច្រៀង ឬ លេងឧបករណ៍ភ្លេងណាមួយ ដើម្បីអោយពួកអ្នកទាំងនោះហាត់ ។ ពួកគេក៏ត្រូវដឹងពេលដែលពួកគេត្រូវប្រគុំដែរ ។ ពួកគេត្រូវចាប់ផ្តើមច្រៀង ដោយមិនចាំបាច់អោយអ្នកដឹកនាំចំរៀងប្រកាសប្រាប់ឡើយ ។ នៅពេលថ្វាយបង្គំ ពួកគេត្រូវច្រៀងចំរៀងតជាប់គ្នា ដោយគ្មានឈប់ ។
- ស្លៀកពាក់អោយបានសមរម្យ នៅពេលចូលរួមក្នុងកម្មវិធីថ្វាយបង្គំ ។ អ្នកដឹកនាំចំរៀងខាងឆ្វេង ត្រូវកែប្រែសភាពខាងក្រៅរបស់គាត់ច្រើនចំណុច ។

តើអ្នកមើលឃើញថា គាត់ចាំបាច់ត្រូវកែប្រែចំណុចណាខ្លះ ? (សូមប្រៀបធៀបអ្នកដឹកនាំចំរៀងខាងឆ្វេង ជាមួយអ្នកដឹកនាំខាងស្តាំ) ។





_____

_____

_____

_____

_____

តើយើងត្រូវចាប់ផ្តើមនៅកន្លែងណា ?

ដើម្បីអាចដឹកនាំមនុស្សបាន យើងត្រូវចាប់ផ្តើមពីសភាពផ្ទាល់របស់មនុស្ស ហើយត្រូវឆាប់មើលដឹងពីសភាពពិតរបស់មនុស្ស ។ គ្រីស្តជនច្រើនតែមកថ្វាយបង្គំ ដោយមានកង្វល់អំពីសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់ពួកគេ និង ចុះខ្សោយខាងជំនឿ ។

អ្នកដឹកនាំចំរៀង ត្រូវជួយពួកគេអោយសំឡឹងមើលទៅព្រះជាម្ចាស់ និងលើកទឹកចិត្តពួកគេ ដោយរបៀបមាំមួន និងពេញដោយសេចក្តីស្រឡាញ់ អោយថ្វាយបង្គំព្រះជាម្ចាស់ដែលគ្រប់គ្រងលើអ្វីៗគ្រប់យ៉ាង ។

យើងអាចមើលឃើញគំរូពីរបៀបដឹកនាំនេះ នៅក្នុងទំនុកតម្កើងចំពួក ១០០ ។ ទំនុកតម្កើងនេះ រៀបរាប់អំពីព្រះពន្លា ដែលលោកម៉ូសេបានកសាង ។ ការយល់អំពីផ្នែកផ្សេងៗរបស់ព្រះពន្លានេះ នឹងជួយយើង អោយអាចមើលឃើញដំណើរការរបស់ការថ្វាយបង្គំ ។

ទីបន្ទាល់

(ទីផ្ការបស់ជំរុំខាងក្រៅរបស់ទីលានដែនៃព្រះពន្លា/អោងឧបោសថ)

ទំនុកតម្កើង ១០០:១-៣ ប្រាប់យើងថា÷ *«ចូរគោរពបំរើព្រះ-អម្ចាស់ ដោយចិត្តរីករាយ...ចូរនាំគ្នាចូលមកជិតព្រះអង្គ ដោយច្រៀងយ៉ាងសប្បាយ ! ចូរដឹងថា ព្រះអម្ចាស់ពិតជាព្រះជាម្ចាស់មែន ! ព្រះអង្គបានបង្កើតយើងមក យើងជាប្រជារាស្ត្ររបស់ព្រះអង្គ ហើយជាប្រជាជនដែលព្រះអង្គថែរក្សា »* ។

ចំរៀងទីបន្ទាល់នាំឱ្យមនុស្សមានឱកាសគិតពីស្ថានភាពរបស់ខ្លួន នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ គឺគេជាបុត្រធីតារបស់ព្រះអង្គ ដោយសារព្រះគ្រីស្ត ។ ជាដំបូង អ្នកដឹកនាំចំរៀង ត្រូវណែនាំមនុស្សអោយច្រៀងចំរៀងដែលនាំឱ្យគេអាចផ្ទៀជីវិត ថ្វាយការតូចចិត្ត ការភ័យខ្លាច និងទុក្ខលំបាករបស់គេទៅព្រះអម្ចាស់ ។

ឧទាហរណ៍ យើងអាចប្រើចំរៀងដែលចាប់ផ្តើមដោយ «ខ្ញុំជា...» ឬ «ខ្ញុំបាន...» ។ យើងប្រើចំរៀងដូចនេះ ដើម្បីបំបែរចិត្តគំនិតមនុស្សអោយងាកចេញពីបញ្ហារបស់ខ្លួន ហើយនាំចិត្តគំនិតពួកគេអោយតម្រង់ឆ្ពោះទៅព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ។ ជំហានបន្ទាប់គឺ «អរព្រះគុណ» ។



- រកអោយឃើញកូនសោភ្លេងរបស់ចំរៀងនិមួយៗ រួចកត់ត្រាទុក ។

- ជ្រើសរើសចំរៀងដោយហ្មត់ចត់ ស្របទៅតាម :
  - មនុស្សដែលនឹងមកចូលរួមថ្វាយបង្គំ
  - លំដាប់លំដោយចំរៀង ក្នុងកម្មវិធីថ្វាយបង្គំ
  - គោលបំណងរបស់កម្មវិធីថ្វាយបង្គំ
  - ប្រធានបទរបស់សេចក្តីអធិប្បាយ ។

  ឧទាហរណ៍ : តើជាចំរៀងសំរាប់ការលន់តួសារភាពអំពើបាប ឬ ការសរសើរតម្កើង ឬ ការអរព្រះគុណ ។ល។ ?

- បន្ទាប់ពីសេចក្តីអធិប្បាយសំរាប់ពួកអ្នកជឿ អ្នកអាចច្រៀងចំរៀងដាស់តឿន ។ ចំរៀងនេះ នឹងអញ្ជើញពួកគេអោយបំពេញភារៈកិច្ចរបស់ពួកគេ ។ ដូចជាបទចំរៀង :
  - « ចូរព្រោះព្រះបន្ទូលទៅ » ឬ
  - « ខ្ញុំរង់ចាំទ្រង់ » ។

អរព្រះគុណ

(ការចូលទៅក្នុងទីលាន)

អ្នកនិពន្ធទំនុកតម្កើងចែងប្រាប់យើងថា÷ *« ចូរនាំគ្នាចូលតាមទ្វារព្រះដំណាក់របស់ព្រះអង្គ ដោយអរព្រះគុណ »* (ទំនុកតម្កើង ១០០:៤) ។ នៅពេលដែលយើងច្រៀងចំរៀងអរព្រះគុណ គឺយើងដើរចូលតាមទ្វារ ដែលបែងចែកអ្វីដែលជាលោកីយ៍ (សាច់ឈាម)ពីអ្វីដែលបរិសុទ្ធ ។

ពេលចូលដល់ក្នុងទីលានព្រះពន្លា ទីមួយ គេឃើញអាសនៈសំរាប់ថ្វាយដង្វាយដុត ។ នៅក្បែរនោះ មានអាងទឹក ។ អាសនៈ និងអាងទឹក មានន័យថា យើងអាចចូលបានតាមរយៈយញ្ញបូជាគ្រប់លក្ខណ៍របស់ព្រះយេស៊ូគ្រីស្ត ដែលសុគតនៅលើឈើឆ្កាង និងការដែលព្រះអង្គលាងសំអាតយើងពីអំពើបាប ។ ដូច្នេះ នេះជាពេលវេលាដ៏ល្អ សំរាប់អរព្រះគុណព្រះជាម្ចាស់ ចំពោះការសុគតនៅលើឈើឆ្កាងរបស់ព្រះយេស៊ូ និងការដែលព្រះអង្គលាងសំអាតយើងពីអំពើបាប ។

នេះក៏ជាឱកាសដ៏ល្អ សំរាប់អរព្រះគុណព្រះជាម្ចាស់អំពីការលើកលែងទោស ដែលព្រះអង្គប្រទានអោយយើងនៅក្នុងអង្គព្រះយេស៊ូគ្រីស្តដែរ ។

«ចំណង់បើព្រះលោហិតរបស់ព្រះគ្រីស្តវិញ តើនឹងរឹតតែជម្រះមនសិការយើងអោយបានរួចផុតពីអំពើឥតបានការ ដើម្បីគោរពបំរើព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ ខ្លាំងយ៉ាងណាទៅទៀត ? គឺដោយសារព្រះវិញ្ញាណ ដែលគង់នៅអស់កល្បជានិច្ច ព្រះគ្រីស្តបានថ្វាយព្រះអង្គផ្ទាល់ទៅព្រះជាម្ចាស់ ទុកជាយញ្ញបូជាឥតសៅហ្មង » ។

(ហេប្រឺ ៩:១៤)



កិច្ចការដែលអ្នកដឹកនាំចំរៀងត្រូវធ្វើជាចាំបាច់

មុនកម្មវិធីថ្វាយបង្គំ

- អធិស្ឋានសំរាប់ការថ្វាយបង្គំ ។ សូមនឹកចាំជានិច្ចថា កម្មវិធីថ្វាយបង្គំ ជាឱកាសសំរាប់ថ្វាយបង្គំព្រះជាម្ចាស់ មិនមែនសំរាប់កំសាន្តចិត្តក្រុមជំនុំទេ ។ យើងថ្វាយបង្គំ ដើម្បីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ និង ដើម្បីកសាងពួកអ្នកជឿអោយរីកចំរើនឡើងក្នុងអង្គព្រះគ្រីស្ត ។

មនុស្សទេ ។ សូមទុកអោយបងប្អូនថ្វាយបង្គំចុះ ។ នៅក្នុងពេលថ្វាយបង្គំ ជួនកាល អ្នកដឹកនាំចំរៀងមានអារម្មណ៍ថា គេត្រូវនិយាយ ឬអធិស្ឋានក្នុងចន្លោះ នៅពេលដែលមានភាពស្ងៀមសាត់នេះ តែគួរទុកឱកាសអោយពួកអ្នក ដែលកំពុងចូលរួមថ្វាយបង្គំ ចូលក្នុងវត្តមានរបស់ព្រះជាម្ចាស់ល្អជាង ។

នៅពេលដែលអ្នកមើលឃើញថា មនុស្សភាគច្រើនថ្វាយបង្គំចប់ហើយ ត្រូវច្រៀងចំរៀងមួយដែលទាក់ទងនឹងប្រធានបទរបស់សេចក្តីអធិប្បាយព្រះបន្ទូល ឬ ឆ្លងចូលទៅសកម្មភាពមួយទៀត ដែលអ្នកបានរៀបចំទុកហើយ ។

ការច្រៀង គឺជាស្ពានទាំយើងអោយថ្វាយបង្គំ ។ ព្រះវិញ្ញាណ-ដ៏វិសុទ្ធ ប្រើចំរៀង ដើម្បីរំដោះវិញ្ញាណរបស់យើង អោយអាចថ្វាយបង្គំព្រះជាម្ចាស់ ។ ចំរៀងនាំអោយអ្នកជឿចេញពីស្ថានភាពសាច់ឈាម ដើម្បីចូលទៅក្នុងស្ថានភាពព្រលឹងវិញ្ញាណ ។ ចំរៀងនាំអោយអ្នកជឿ ឆ្លងពីការបង្ហាញពីសេចក្តីត្រូវការរបស់ខ្លួនទៅថ្វាយបង្គំព្រះជាម្ចាស់ ដោយវិញ្ញាណ ។ ការដឹកនាំចំរៀងមិនមែនគ្រាន់តែជាការដឹកនាំមនុស្សអោយច្រៀងទេ តែជាការដឹកនាំអោយមនុស្សថ្វាយបង្គំ ។



ព្រះពន្លា / រោងឧបោសថ



ការសរសើរតម្កើង

(នៅក្នុងទីសក្ការៈ)

នៅពេលដែលយើងបានច្រៀងចំរៀងអរព្រះគុណរួចហើយ នោះងាយស្រួលនឹងឈានចូលដល់ការសរសើរតម្កើង ។ យើងឈានពីការអរព្រះគុណ ចំពោះការសុគតរបស់ព្រះយេស៊ូ ហើយចូលទៅដល់ការសរសើរតម្កើងព្រះជាម្ចាស់អំពីកិច្ចការដ៏ធំបំផុតផ្សេងៗទៀត ។

ដើម្បីឆ្លងពីជំហានមួយទៅជំហានមួយទៀត អ្នកដឹកនាំចំរៀង មិនចាំបាច់និយាយច្រើនពេកទេ ។ ពេលដែលការថ្វាយបង្គំឈានដល់ការសរសើរតម្កើងនេះ (ការចូលមកដល់វត្តមានដ៏វិសុទ្ធរបស់ព្រះជាម្ចាស់) ត្រូវប្រយ័ត្នកុំអោយបង្អាក់ការហូររបស់ចំរៀង ។ សូមកុំប្រកាសដំណឹង ឬ អធិស្ឋានសំរាប់សេចក្តីត្រូវការរបស់អ្នកដទៃ ។ ត្រូវទុកការអធិស្ឋាន និងការប្រកាសដំណឹងសំរាប់ធ្វើពេលផ្សេងវិញ ។

ការថ្វាយបង្គំ

(នៅក្នុងទីសក្ការៈបំផុត)

នៅពេលដែលយើងចូលទៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ យើងប្រើចំរៀងអំពីព្រះចេស្តា សិរីល្អ និងភាពខ្ពស់ឧត្តមរបស់ព្រះជាម្ចាស់ ព្រមទាំងវត្តមានរបស់ព្រះអង្គ ។ អ្នកនិពន្ធទំនុកតម្កើងនិយាយថា÷ *«ចូរសរសើរតម្កើងព្រះនាមព្រះអង្គ »* (ទំនុកតម្កើង ១០០:៤) ។ យើងចាប់ផ្តើមដោយច្រៀងចំរៀងទីបន្ទាល់នៅក្នុងទីធ្លានៃជំរុំខាងក្រៅទីលាន ហើយយើងបញ្ចប់ដោយច្រៀងថ្វាយទៅព្រះជាម្ចាស់ផ្ទាល់ នៅក្នុងទីសក្ការៈបំផុត ។ នៅពេលដែលយើងឈានចូលជ្រៅទៅក្នុងការថ្វាយបង្គំ យើងឈានពីការថ្វាយបង្គំដោយគ្រាន់តែប្រើពាក្យសំដី ទៅថ្វាយបង្គំព្រះជាម្ចាស់ដោយវិញ្ញាណ ។

នៅត្រង់ចំណុចនេះ អ្នកដឹកនាំខ្លះធ្វើខុសដោយកញ្ឆក់ទាញមនុស្សអោយថយក្រោយមកទីលានវិញ ដោយច្រៀងចំរៀងអរព្រះគុណមួយដែលនាំអោយរំភើបចិត្ត ។ ការថ្វាយបង្គំត្រូវការពេលវេលាច្រើនបន្តិច ។ ដូច្នេះ សូមកុំបង្ខំមនុស្សអោយថ្វាយបង្គំ ដោយប្រញាប់ប្រញាល់ ។ ពេលនេះមិនត្រូវនិយាយអ្វីដែលមកពីប្រាជ្ញា